សេរីភាព របស់មនុស្ស

សេរីភាព របស់មនុស្ស

សមត្ថភាព សមាយោគ[1] ដែលធ្វើអោយមនុស្ស ជា ម៉ាស៊ីន នៃ ប្រជ្ញា លើសសត្វ មិនមែនស្ថិតនៅត្រង់ថា មនុស្ស ជា សត្វ លោក ខ្ពង់ខ្ពស់ជាង សត្វ នោះទេ គឺ វាស្ថិតនៅលើ សមត្ថភាព ដែលមនុស្ស អាចមានលទ្ធភាព ជ្រើសរើស រវាង សកម្មភាព ពីរ ឬ ច្រើនយ៉ាង ដែលមាន សីលធម៌ ក្នុងចំណោមនោះ។ សីលធម៌ នោះ គឺ បញ្ជូលព្រមគ្នា នូវ ធម្មជាតិផ្ទាល់ របស់ខ្លួនជាមនុស្ស, បរស្ថានធម្មជាតិ ដែលខ្លួនរស់នៅ និង ច្បាប់ នៃ ធម្មជាតិ។ ដូច្នេះ ជម្រើសណាមួយ ដែល មនុស្ស ជ្រើសយក វា មិនមែន ជា ជម្រើសធម្មតា ទៅតាម គណនារក ប្រយោជន៍ តិច ឬ ច្រើន និង ជ័យជំនះរួម របស់ តណ្ហា និង សភាវគតិ ទៅលើ វិនិយ របស់ខ្លួនផ្ទាល់ តែប៉ុណ្ណោះទ្បើយ ព្រោះ សក្តិយស ពិសេស របស់ មនុស្ស គឺ សេរីភាព នៃ ជម្រើស របស់ខ្លួន ក្នុងហាន: ជា មនុស្ស មានប្រាជ្ញា ហ្នឹងឯង។ តែ មនុស្ស ដោយសារខ្លួន មាន ភាវរូប ដូច សត្វ វាអាច ចាត់ទុកដែរ ជា ភាវរូបដុល ប្រមូលរួមសំរេច នូវ សេចក្តីត្រូវការ, សភាវគតិ, តណ្ហា និង ការងប់ងល់ គ្រប់ បែបយ៉ាង ដែល វាមានប្រតិកម្ម រវាងគ្នានិងគ្នា នៅក្នុងប្រការ សាំញ ុ តែ នៅទីបំផុត ការប្រមូលរួមទាំងនោះ ជា ចលនាចក្រ

[1] សមត្ថភាព សមាយោគ ; capacité combinatoire។

សេរីភាព របស់មនុស្ស

(mécanique) សំរាប់ សំគាល់ នូវ ចរិត របស់មនុស្ស ដែល វា ក្ខានមាន ចំពោះសត្ថ។ ដូចនេះ មនុស្សម្នាក់ មាន ការឃ្លាន ហើយ ស្វែងរក ម្ហូបចំណី សំរាប់ បំបាត់ គំលាន របស់ខ្លួន ដូច សត្ថពិត តែមានចរិត នៅក្នុង ចលនាចក្រ។ ដូច្នេះ មនុស្ស ជា ម៉ាស៊ីន ធម្មតា តែ ជា ម៉ាស៊ីន ដែល រួមបញ្ចូលគ្រឿងជាច្រើន ដើរ ទៅតាម សារព័ន នៃ វិធានទាំងឡាយមួយ ស្លុកស្ទាញជាង ម៉ាស៊ីន នៃ សត្ថ។ ដូចនេះ សត្ថ មាន សភាវគតិ នៃ ការរក្សា ជីវិត តែ សេចក្តីត្រូវការ របស់មនុស្ស វា មានប្រៀបលើ សភា វគតិ របស់សត្ថ ព្រោះ មនុស្ស មាន វិចារណញ្ញាណ មានការអប់រំ ដែល ជា មរតក នៃ ការវិត្តន៍ នៃ មនុស្សជាតិ។ ម្លោះហើយ សេរី ភាព មិនមែនគ្រាន់តែ ជា បាតុភូត នៃចិត្តនិយម តែប៉ុណ្ណោះ ឡើយ គឺ វាជា អត្តរស់ពិសេស របស់មនុស្សជាតិ តែម្តង។ សេរី ភាព ពុំមែន មានន័យថា មនុស្ស ត្រូវរស់ នៅក្នុងធម្មជាតិ ឬ តាមច្បាប់ធម្មជាតិនោះទេ ផ្ទុយទៅវិញ សេរីភាព ចាប់ផ្តើម មាននៅទីណា ឬ ពេលណា ដែលក្ខានធម្មជាតិ គឺថា មនុស្ស អាច មាន ជម្រើស យកផ្លូវសីលធម៌ ដោយខ្លួនឯង សំរាប់ខ្លួន ឯង ក្នុងចំណោមផ្លូវទាំងឡាយ។ ការប្រយុទ្ធ របស់មនុស្ស ដើម្បី អោយមានការទទួលស្គាល់ នូវទំហំសីលធម៌នោះ គឺជា ចលការ នៃ អភិវឌ្ឍន៍ នៃ សារម្ភកថា[2] ក្នុង ប្រវត្តិសាស្ត្រ។

[2] សារម្ភកថា[2], dialectique, សម្តីប្រណាំងប្រជែង, ពាក្យប្រកួតប្រណាំង។